ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

លេខ : ០៣៤១ ដនស / អសណមក

ថ្ងៃច័ន្ទ ៣កើត ខែជេស្ឋ ឆ្នាំខាលចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០២២

**ជម្រាបជូន**

**លោកប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី និងខេត្ត**

**កម្មវត្ថុ** ៖ ការកែសម្រួលរូបមន្តក្នុងការចុះបញ្ជីអចលនវត្ថុជាប្រភេទទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធណាម្នាក់ ដែលស្ថិតក្នុងស្ថានភាពស៊ីវិល "ពោះម៉ាយ" ឬ "មេម៉ាយ" ដោយសារមរណភាពរបស់សហព័ទ្ធម្ខាងទៀត និងកែសម្រួលលើរូបមន្តនិងឯកសាររណបផ្សេងទៀត ដែលធ្លាប់ប្រើពាក្យ "ខ្មោច" ទៅជាពាក្យ "មតកជន" វិញ ដោយអនុលោមតាមក្រមរដ្ឋប្បវេណី

**យោង** ៖ -ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណី

-ព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី

-ចំណារ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **លោកប្រធានមន្ទីរ** ជ្រាបថា កន្លងមក ការចុះបញ្ជីអចលនវត្ថុ និងចេញបណ្ណសម្គាល់សិទ្ធិឬវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ដែលជាទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធណាម្នាក់ "ទ្រព្យខាងប្តី(PM) ឬទ្រព្យខាងប្រពន្ធ(PF)" ដែលស្ថិតក្នុងស្ថានភាពស៊ីវិល "ពោះម៉ាយ" ឬ "មេម៉ាយ" ដោយមូលហេតុមរណភាពរបស់សហព័ទ្ធម្ខាងទៀត ត្រូវបានកំណត់ដោយរូបមន្តដែលសរសេរថា ៖

(១)ករណីទ្រព្យសម្បត្តិដោយឡែកខាងប្តី ឧទាហរណ៍ សុខ សាន (ពោះម៉ាយពីខ្មោចនាង ច័ន្ទ រតនា)

(២)ករណីទ្រព្យសម្បត្តិដោយឡែកខាងប្រពន្ធ ឧទាហរណ៍ នាង ច័ន្ទ រតនា (មេម៉ាយពីខ្មោច សុខ សាន)។

ពាក្យ "ខ្មោច" ដែលប្រើនៅក្នុងរូបមន្តខាងលើ ជាពាក្យដែលប្រើនៅក្នុងក្រមរដ្ឋប្បវេណីចាស់ ប៉ុន្តែបច្ចុប្បន្នមានក្រមរដ្ឋប្បវេណីថ្មីដែលបានផ្លាស់ប្តូរប្រើពាក្យពេចន៍ថ្មីៗជាច្រើនជំនួសពាក្យពេចន៍ចាស់ៗ ដែលធ្លាប់ប្រើនៅក្នុងក្រមរដ្ឋប្បវេណីចាស់ ក្នុងនោះ ក៏មានពាក្យ "ខ្មោច" ផងដែរ ដែលត្រូវបានជំនួសដោយពាក្យថ្មីគឺ "មតកជន" ដែលមានន័យថា ជនឬបុគ្គលដែលបានស្លាប់ទៅហើយ។ ដូចនេះ ក្រសួងសម្រេចឱ្យកែសម្រួលរូបមន្តលេខ(១) និងលេខ(២)ខាងលើ ដោយប្រើពាក្យ "មតកជន" ជំនួសពាក្យ "ខ្មោច" តាមលំនាំដូចខាងក្រោម ៖



Scanned with CamScanner

(៣)ករណីទ្រព្យសម្បត្តិដោយឡែកខាងប្ដី ត្រូវសរសេរថា ឧទាហរណ៍ សុខ សាន (ពោះម៉ាយពីមតកជន ច័ន្ទ រតនា)

(៤)ករណីទ្រព្យសម្បត្តិដោយឡែកខាងប្រពន្ធ ត្រូវសរសេរថា ឧទាហរណ៍ នាង ច័ន្ទ រតនា (មេម៉ាយពីមតកជន សុខ សាន)

ក្រៅពីរូបមន្តនៃករណីខាងលើ ក្រសួងអនុញ្ញាតឱ្យកែសម្រួលរូបមន្ត និងឯកសារណាផ្សេងៗទៀត ដែលធ្លាប់ប្រើពាក្យ "ខ្មោច" ជំនួសដោយពាក្យ "មតកជន"វិញផងដែរ។

ដើម្បីអនុវត្តរូបមន្តថ្មីលេខ(៣)និងលេខ(៤) ក្រសួងនឹងចាត់មន្ត្រីជំនាញនៃអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រចុះសហការជាមួយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី និងខេត្តទាំងអស់ ដើម្បីដំឡើងរូបមន្តថ្មីជំនួសរូបមន្តចាស់នៅក្នុងប្រព័ន្ធមូលដ្ឋានទិន្នន័យ (Database system) សម្រាប់ការប្រើប្រាស់តរៀងទៅ។

អាស្រ័យហេតុនេះ សូម **លោកប្រធានមន្ទីរ** ជ្រាប និងមុខការ។

សូម **លោកប្រធានមន្ទីរ** ទទួលនូវការរាប់អានពីខ្ញុំ។

**ជ.រដ្ឋមន្ត្រី**

**រដ្ឋលេខាធិការប្រចាំការ**

**ឆាន់ សាផាន**

**ចម្លងជូន ÷**

-អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ

-ឯកសារ-កាលប្បវត្តិ

CS Scanned with CamScanner